ក N°40/16 ▸31/5/2016

# មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១១-៥-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៦/៥១២ ស្តីពី ការបញ្ចប់តំណែងឯកឧត្តម **ព្រុំ សុភមង្គល** ពីអគ្គលេខាធិការ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន មានឋានៈស្មើ រដ្ឋមន្ត្រី និងតែងតាំងជាអនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ៤៦១៣ |
| ១១-៥-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៦/៥១៣ ស្តីពី ការតែងតាំងឯកឧត្តម **លី ធុជ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រធានទី ២ អាជ្ញាធរមីន ជាអគ្គលេខាធិការ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន បន្ថែមលើមុខងារបច្ចុប្បន្ន | ៤៦១៤ |
| ១១-៥-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៦/៥១៤ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ម៉ៅ សមយុទ្ធ** ជាទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ដោយពុំទទួលយកប្រាក់បៀវត្ស | ៤៦១៥ |
| ១១-៥-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៦/៥១៥ ស្តីពី ការផ្ទេរក្របខ័ណ្ឌលោក **សុគន្ធ វិសិដ្ឋ** នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មកឋានន្តរស័ក្តិ ឧត្តម សេនីយ៍ត្រី ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ | ៤៦១៦ |
| ១១-៥-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៦/៥១៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **វ៉ាង សាវជុន** (WANG SHAOCHUN) ជនជាតិចិន សញ្ជាតិចិន | ៤៦១៧ |
| ១១-៥-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៦/៥១៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ណៃ សុង គៀត** (NAI SONG KIAT) ជនជាតិសិង្ហបុរី សញ្ជាតិសិង្ហបុរី | ៤៦១៨ |
| ១៤-៥-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៦/៥១៨ ស្តីពី ការតែងតាំងឯកឧត្តម **គុយ សុផល** ជាឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន | ៤៦១៩ |

១៧-៥-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៥១៦/៥១៩ ស្តីពី ការបន្ថយរយៈពេលទទួលរងទោសឱ្យទណ្ឌិត ចំនួន ៧៦ នាក់ និងលើកលែងទោសឱ្យទណ្ឌិតចំនួន ០៣ នាក់ ក្នុងឱកាសបុណ្យពិសាខបូជា ឆ្នាំ ២០១៦ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ៤៦២០

## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ

១២-៥-២០១៦ -អនុក្រឹត្យលេខ ៩៨ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៤៦៣២
១២-៥-២០១៦ -អនុក្រឹត្យលេខ ៩៩ អនក្រ.បក ស្តីពី ការកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៨ ៤៦៣៤
២៣-៥-២០១៦ -អនុក្រឹត្យលេខ ១០០ អនក្រ.បក ស្តីពី ការបង្កើតតំបន់ការពារទេសភាពអាងត្រពាំងថ្ម ៤៦៣៩
១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៥០ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែង និងលុបឈ្មោះមន្ត្រីរាជការ ៤៦៤៣
១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៥១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៦៤៤
១១-៥-២០១៦ -អនុក្រឹត្យលេខ ៥៥២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៦៤៥
១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៥៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៦៤៧
១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៥៤ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៤៦៤៩
១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៥៥ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៤៦៥០
១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៥៦ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយនគរបាលជាតិ ៤៦៥១
១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៥៧ អនក្រ.តត ស្តីពី ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤៦៥២
១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៥៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៦៥៤
១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៥៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៦៥៦
១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៦០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៦៥៨
១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៦១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៤៦៥៩
១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៦២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៤៦៦០

១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៦៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៤៦៦១

១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៦៤ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ៤៦៦៣

១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៦៥ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៤៦៦៨

១២-៥-២០១៦ -អនុក្រឹត្យលេខ ៥៦៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៦៦៩

១៣-៥-២០១៦ -អនុក្រឹត្យលេខ ៥៦៧ អនក្រ.តត ស្តីពី ការតែងតាំង ប្រគល់ភារកិច្ច និងសម្រួលភារកិច្ចមន្ត្រីរាជការ ៤៦៧១

១៣-៥-២០១៦ -អនុក្រឹត្យលេខ ៥៦៨ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៤៦៧៣

១៣-៥-២០១៦ -អនុក្រឹត្យលេខ ៥៦៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៦៧៤

១៣-៥-២០១៦ -អនុក្រឹត្យលេខ ៥៧០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៦៧៩

១៣-៥-២០១៦ -អនុក្រឹត្យលេខ ៥៧១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៤៦៨៤

២៣-៥-២០១៦ -អនុក្រឹត្យលេខ ៥៧២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៤៦៨៥

២៣-៥-២០១៦ -អនុក្រឹត្យលេខ ៥៧៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៤៦៨៦

២៣-៥-២០១៦ -អនុក្រឹត្យលេខ ៥៧៤ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ៤៦៩១

២៣-៥-២០១៦ -អនុក្រឹត្យលេខ ៥៧៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៦៩២

២៣-៥-២០១៦ -អនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៦៩៤

២៣-៥-២០១៦ -អនុក្រឹត្យលេខ ៥៧៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៦៩៦

២៣-៥-២០១៦ -អនុក្រឹត្យលេខ ៥៧៨ អនក្រ.តត ស្តីពី ការតែងតាំង តម្លើងឋានៈគ្រូនគរបាលជាតិកម្ពុជា ៤៦៩៧

២៣-៥-២០១៦ -អនុក្រឹត្យលេខ ៥៧៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៤៧០០

២៥-៥-២០១៦ -អនុក្រឹត្យលេខ ៥៨០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៧០២


## III-ការងារបណ្ដាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១៨-៣-២០១៦ -ប្រកាសអន្តរក្រសួងលេខ ២៧៦ សហវ.ប្រក ស្តីពី ការតែងតាំងរដ្ឋទេយ្យករបុរេប្រទានរបស់ក្រសួងព័ត៌មាន ៤៧០៨

១៧-៣-២០១៦ -ប្រកាសលេខ ២៧៧ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ៤៧១០

១៨-៣-២០១៦ -ប្រកាសអន្តរក្រសួងលេខ ២៧៨ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ ៤៧១៦

១៨-៣-២០១៦ -ប្រកាសអន្តរក្រសួងលេខ ២៨០ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ៤៧២០


## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម


០៣-៣-២០១៦ -ប្រកាសលេខ ១៦១ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អិម ភីក អេ ស៊ី អិម ស៊ី (ខេមបូឌា) បង្កើតរោងចក្រ ផលិតចំណីសត្វ ៤៧២៤

០៣-៣-២០១៦ -ប្រកាសលេខ ១៦២ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហួនីង ខេមបូ បង្កើតរោងចក្រ ចាក់ និងកាត់ដេរសម្លៀកបំពាក់ ៤៧២៧

០៣-៣-២០១៦ -ប្រកាសលេខ ១៦៣ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ិន ហ្វុង (ខេមបូឌា) ហ្គាមិនត៍ បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៤៧៣០

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៦/៥១២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: បញ្ចប់តំណែងឯកឧត្តម ព្រុំ សុភមង្គល ពីអគ្គលេខាធិការ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន មានឋានៈស្មើ រដ្ឋមន្ត្រី ។

**មាត្រា ២**: តែងតាំងឯកឧត្តម ព្រុំ សុភមង្គល ជាអនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ៣**: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការស. ១៦០៥.៥១៨

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦

លេខ: ៥០៧ស.ណ

សំណៅចម្លងចេញពីច្បាប់ដើម ដែលមានតម្លៃជាការចេញផ្សាយ

រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៦/៥១៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្មមាត្រា ៤, ១០ និង ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/ ១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំងឯកឧត្តម **លី ធុជ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រធានទី ២ អាជ្ញាធរមីន ជា អគ្គលេខាធិការ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៦០៥.៥១៩

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦

លេខៈ ៥០៦ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៦/៥១៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង និងផ្តល់ឋានៈឯកឧត្តម **ម៉ៅ សមយុទ្ធ** ជាទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើអគ្គនាយក ដោយពុំទទួលយកប្រាក់បៀវត្ស។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤. ១៦០៥. ៥២០

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦

លេខៈ ៥១២ ស.ណ

**សំណៅចែលមិនអម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៦/៥១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌលោក **សុគន្ធ ចិត្តសិដ្ឋ** ពីឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ថ្នាក់លេខ២ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មកឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** អត្តលេខ ៧៨០១៩ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧រព. ១៦០៥. ៥៤១

**លេខៈ ៥១៦ ស.ណ**
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៦**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៦/៥១៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វ៉ាង សាវជុន** (WANG SHAOCHUN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧១ នៅខេត្តសានទុង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣៧៧. ១៦០៥.៥៤២

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦*

លេខ: ៥០៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៦/៥១៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ណៃ សុង គៀត** (NAI SONG KIAT) ជនជាតិសិង្ហបុរី សញ្ជាតិសិង្ហបុរី កើតថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៥២ នៅទីក្រុងសិង្ហបុរី សាធារណរដ្ឋសិង្ហបុរី។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៨.១៦០៥.៥៤៣

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦*

លេខៈ ៥០៨ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៦/៥១៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង

ឯកឧត្តម គុយ សុផល

ជា

ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
បន្ថែមលើមុខងារបច្ចុប្បន្ន

នរោត្តម សីហមុនី

៣ភស.១៦០៥.៥២៤
បានប្រទាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៦

បានចុះបញ្ជីតាមច្បាប់ដើម
លេខ ០៣២/១៦ រ.ចប
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៦
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីធរា គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៦/៤១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ខែ ឱ្យទណ្ឌិតចំនួន ៣០នាក់ ក្នុងឱកាសបុណ្យពិសាខបូជា ឆ្នាំ២០១៦ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោម៖

១-ទណ្ឌិតឈ្មោះ **ឆុន ឆុយ** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-៦-២០១២ ពីបទ ឃាតកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥៥ "ឆ" ចុះថ្ងៃទី ២៦-១២-២០១២ របស់សាលាដំបូងខេត្តកោះកុង ។

២-ទណ្ឌិតឈ្មោះ **ថុង សុខុម** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-៩-២០១៣ ពីបទ ធ្វើឱ្យខូចខាតដោយចេតនាដោយមានស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់វិធីគ្រោះថ្នាក់ដល់បុគ្គល ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ "ឃ" ចុះថ្ងៃទី ១៨-៣-២០១៤ របស់សាលាដំបូងខេត្តប៉ៃលិន ។

៣-ទណ្ឌិតឈ្មោះ **តាំង សុវណ្ណ** ហៅ យ៉ុង ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣០-៥-២០១៤ ពីបទ រំលោភលើទំនុកចិត្ត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ១៩ "ក" ចុះថ្ងៃទី ០២-១០-២០១៤ របស់សាលាដំបូងខេត្តប៉ៃលិន ។

៤-ទណ្ឌិតឈ្មោះ **ឌី រតនា** ហៅ ក្របី ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៧-៨-២០១១ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ "ខ" ចុះថ្ងៃទី ៣០-០១-២០១២ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

៥-ទណ្ឌិតឈ្មោះ **ឆេង សុភឃី** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-៩-២០១៣ ពីបទ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ "ខ" ចុះថ្ងៃទី ១៥-០១-២០១៤ របស់សាលាដំបូងខេត្តកំពង់ចាម ។

៦-ទណ្ឌិតឈ្មោះ **អោក ធារិត** ហៅ ដា ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-៧-២០១២ ពីបទ នាំយកអនីតិជនចេញដោយមិនស្របច្បាប់ និងរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧ "ជ" ចុះថ្ងៃទី ១២-៦-២០១៣ របស់សាលាដំបូងខេត្តកំពង់ចាម ។

៧-ទណ្ឌិតឈ្មោះ **ស៊ីត គី** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២១-០១-២០១២ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ "ញ" ចុះថ្ងៃទី ០៧-០២-២០១៣ របស់សាលាដំបូងខេត្តកំពង់ចាម ។

៨-ទណ្ឌិតឈ្មោះ **ផាត សុមី** ហៅ ភា ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-៧-២០១៣ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ "ឋ" ចុះថ្ងៃទី ០៤-០២-២០១៤ របស់សាលាដំបូងខេត្តកំពង់ចាម ។

៩-ទណ្ឌិតឈ្មោះ **នី សុខជា** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-៩-២០១២ ពីបទ អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ "ឃ" ចុះថ្ងៃទី ០៤-៤-២០១៣ របស់សាលាដំបូងខេត្តកំពង់ចាម ។

ROYAUME DU CAMBODGE — LE MINISTERE DU PALAIS ROYAL

១០-ទណ្ឌិតឈ្មោះ **ហ៊ាន ទិត** ហៅ មៅ ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-១០-២០០៩ ពីបទ នាំយកមនុស្សចេញដោយមិនស្របច្បាប់សម្រាប់ការឆ្លងដែន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៤ "ឃ" ចុះថ្ងៃទី ០៧-៦-២០១០ របស់សាលាដំបូងខេត្តកំពង់ចាម ។

១១-ទណ្ឌិតឈ្មោះ **ភខ ស្រីល័ក្ខ** ភេទស្រី អាយុ ៣៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៧-៥-២០១៣ ពីបទ សញ្ចារកម្ម (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងចារី) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩ "ឈ" ចុះថ្ងៃទី ២៧-០១-២០១៤ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

១២-ទណ្ឌិតឈ្មោះ **ហឿម ជរ** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-៦-២០១១ ពីបទ ប្រើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧ "ខ" ចុះថ្ងៃទី ១៥-១១-២០១១ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ។

១៣-ទណ្ឌិតឈ្មោះ **ស៊ិន សុវណ្ណា** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៧-២០១១ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយកាត់អវៈយវៈ ឬពិការភាព ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៩ "ជ" ចុះថ្ងៃទី ០៣-៤-២០១២ របស់សាលាដំបូងខេត្តសៀមរាប ។

១៤-ទណ្ឌិតឈ្មោះ **រស់ តីម៉ូរ៉ា** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-៦-២០១១ ពីបទ រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ "ក" ចុះថ្ងៃទី ១៥-០២-២០១២ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ។

១៥-ទណ្ឌិតឈ្មោះ **រ៉េត រ័ត្ន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-៩-២០១១ ពីបទ រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ "ឈ" ចុះថ្ងៃទី ២៦-០១-២០១២ របស់សាលាដំបូងខេត្តសៀមរាប។

១៦-ទណ្ឌិតឈ្មោះ **ផុន ហាត** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៨-២០១១ ពីបទ រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២៣ "ង" ចុះថ្ងៃទី ២៨-១១-២០១១ របស់សាលាដំបូងខេត្តសៀមរាប។

១៧-ទណ្ឌិតឈ្មោះ **សំពៅ សាទិត** ហៅ វិត ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-៣-២០១២ ពីបទ រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនក្មេងស្ទើស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៥ "ញ" ចុះថ្ងៃទី ០៧-៨-២០១២ របស់សាលាដំបូងខេត្តសៀមរាប ។

១៨-ទណ្ឌិតឈ្មោះ **មុត ម៉ៅ** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១០-១២-២០១២ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ "ថ" ចុះថ្ងៃទី ០៥-៦-២០១៣ របស់សាលាដំបូងខេត្តសៀមរាប ។

១៩-ទណ្ឌិតឈ្មោះ **សាលី ម៉ុនញ៉ា** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៦-២០១១ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលដីកាលេខ ១០៨ "ក្រIVអ" ចុះថ្ងៃទី ១៩-៦-២០១៣ របស់សាលាឧទ្ធរណ៍ ។

២០-ទណ្ឌិតឈ្មោះ **ចាន់ ពលៈ** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-១២-២០១១ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ២៦ "ក្រVIញ" ចុះថ្ងៃទី ១០-៦-២០១៤ របស់សាលាឧទ្ធរណ៍ ។

២១-ទណ្ឌិតឈ្មោះ **ភ្រឹម សួន** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-១០-២០១៣ ពីបទ ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ "ឋ" ចុះថ្ងៃទី ០៥-០២-២០១៤ របស់សាលាដំបូងខេត្តសៀមរាប ។

២២-ទណ្ឌិតឈ្មោះ **ផាន់ រើន** ហៅ ជាត់ ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-១២-២០១៣ ពីបទ រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧ "ណ" ចុះថ្ងៃទី ២៨-៤-២០១៤ របស់សាលាដំបូងខេត្តសៀមរាប។

២៣-ទណ្ឌិតឈ្មោះ **សេខ លី** ហៅ ឡី ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៣-២០១៤ ពីបទ ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧ "ញ" ចុះថ្ងៃទី ២០-៨-២០១៤ របស់សាលាដំបូងខេត្តសៀមរាប ។

២៤-ទណ្ឌិតឈ្មោះ **ឆេម ត្ង** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣១-១០-២០១៣ ពីបទ រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ ៥ ខែ តាមអំណាចសាលក្រមលេខ ១៣ "ង" ចុះថ្ងៃទី ០៦-៣-២០១៤ របស់សាលាដំបូងខេត្តសៀមរាប។

២៥-ទណ្ឌិតឈ្មោះ **ព្រោម ពន់** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៧-៧-២០១៤ ពីបទ រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦០ "ឌ" ចុះថ្ងៃទី ០២-១២-២០១៤ របស់សាលាដំបូងខេត្តសៀមរាប ។

២៦-ទណ្ឌិតឈ្មោះ **ឆៀង ម៉ុនធឿត** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៤-៥-២០១៤ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៩ "ខ" ចុះថ្ងៃទី ២២-១២-២០១៤ របស់សាលាដំបូងខេត្តសៀមរាប ។

២៧-ទណ្ឌិតឈ្មោះ **ហាម ឈិន** ភេទស្រី អាយុ ៥៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-៨-២០១៤ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦ "ជ" ចុះថ្ងៃទី ២៦-៣-២០១៥ របស់សាលាដំបូងខេត្តសៀមរាប ។

២៨-ទណ្ឌិតឈ្មោះ **អាត់ អួច** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១០-១២-២០១៣ ពីបទ បង្ករបួសដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៥ "ខ" ចុះថ្ងៃទី ១១-៦-២០១០ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

២៩-ទណ្ឌិតឈ្មោះ **អេង សំអឿន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៦-៦-២០១០ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ "ក" ចុះថ្ងៃទី ១៨-០១-២០១១ របស់សាលាដំបូងខេត្តបាត់ដំបង ។

៣០-ទណ្ឌិតឈ្មោះ **ផាន រិត** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-៣-២០១១ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៦ "ង" ចុះថ្ងៃទី ២៧-១២-២០១១ របស់សាលាដំបូងខេត្តបាត់ដំបង ។

**មាត្រា ២:** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ខែ ឱ្យទណ្ឌិតចំនួន ២០នាក់ ក្នុងឱកាសបុណ្យពិសាខបូជា ឆ្នាំ២០១៦ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោម៖

១-ទណ្ឌិតឈ្មោះ **សៀង ឧុទ្ធី** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១១-០២-២០១០ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៦ "ច" ចុះថ្ងៃទី ០២-៩-២០១០ របស់សាលាដំបូងខេត្តកំពង់ធំ ។

២-ទណ្ឌិតឈ្មោះ **ខេង ឌៀង** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-៤-២០១១ ពីបទ ឃាតកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥ "ឃ" ចុះថ្ងៃទី ១៥-១១-២០១១ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

ROYAUME DU CAMBODGE • LE SECRÉTARIAT DU PALAIS ROYAL • ព្រះរាជវាំង

៣-ទណ្ឌិតឈ្មោះ **ឃិន ម៉ុន** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៥-២០០៩ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣០ "ក" ចុះថ្ងៃទី ០១-៤-២០១០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

៤-ទណ្ឌិតឈ្មោះ **ម៉ៅ ឈឹន** ភេទប្រុស អាយុ ៥៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៤-២០១១ ពីបទ ឃាតកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៩ "ខ" ចុះថ្ងៃទី ១២-១០-២០១១ របស់សាលាដំបូងខេត្តកំពង់ចាម ។

៥-ទណ្ឌិតឈ្មោះ **អៀម រិត** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០២-៤-២០១០ ពីបទ ឃាតកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥ "ឃ" ចុះថ្ងៃទី ២៤-១១-២០១១ របស់សាលាដំបូងខេត្តកំពង់ចាម ។

៦-ទណ្ឌិតឈ្មោះ **ចាន់ ឃីម** ភេទប្រុស អាយុ ៥៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-១២-២០០៧ ពីបទ ធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦២ "គ" ចុះថ្ងៃទី ១៦-១២-២០០៨ របស់សាលាដំបូងខេត្តកំពង់ចាម ។

៧-ទណ្ឌិតឈ្មោះ **ឈឿន ឡា** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៧-២០០៥ ពីបទ ធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ "ខ" ចុះថ្ងៃទី ១៣-០១-២០០៦ របស់សាលាដំបូងខេត្តកំពង់ចាម ។

៨-ទណ្ឌិតឈ្មោះ **ឃុត ដេច** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-៤-២០០៧ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៣ "ច" ចុះថ្ងៃទី ០២-១០-២០០៧ របស់សាលាដំបូងខេត្តកំពង់ចាម ។

៩-ទណ្ឌិតឈ្មោះ **ណាក ឈុនឡេង** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-៤-២០០៨ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ "ខ" ចុះថ្ងៃទី ១០-៣-២០០៩ របស់សាលាដំបូងខេត្តកំពង់ចាម ។

១០-ទណ្ឌិតឈ្មោះ **ខាត់ សំអាន** ភេទប្រុស អាយុ ៤៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-០១-២០០៨ ពីបទ ប៉ុនប៉ងធ្វើមនុស្សឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៥ "ខ" ចុះថ្ងៃទី ០៦-៨-២០០៨ របស់សាលាដំបូងខេត្តកំពង់ចាម ។

១១-ទណ្ឌិតឈ្មោះ **ហ៊ត់ គង់** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-០១-២០០៨ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៥ "ឆ" ចុះថ្ងៃទី ១០-៣-២០០៩ របស់សាលាឧទ្ធរណ៍ ។

១២-ទណ្ឌិតឈ្មោះ **យ៉េន សិត** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-៥-២០១០ ពីបទ អំពើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៤ "ឆ" ចុះថ្ងៃទី ២៩-៩-២០១០ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៣-ទណ្ឌិតឈ្មោះ **សែម ស៊ីត់** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៦-០១-២០០៧ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ "ជ" ចុះថ្ងៃទី ១៨-៧-២០០៧ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៤-ទណ្ឌិតឈ្មោះ **សយ ធឿន** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៤-២០០៧ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ "គ" ចុះថ្ងៃទី ២០-៥-២០០៨ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៥-ទណ្ឌិតឈ្មោះ **ចាន់ ទិមាន** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៦-២០០៩ ពីបទ ផ្តើមគំនិតក្នុងអំពើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩០ "ឃ" ចុះថ្ងៃទី ២៣-៩-២០១០ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៦-ទណ្ឌិតឈ្មោះ **អ៊ា ឈឿន** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-៤-២០១១ ពីបទ ហិង្សាដោយមានស្ថានទម្ងន់ទោសដោយសារមរណភាព នៃជនរងគ្រោះ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៤ "ឆ" ចុះថ្ងៃទី ៣០-១១-២០១១ របស់សាលាដំបូងខេត្តសៀមរាប ។

១៧-ទណ្ឌិតឈ្មោះ **ឈឺន រុន** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៥-២០០៧ ពីបទ អំពើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៣៦ "ង" ចុះថ្ងៃទី ២៧-១០-២០០៩ របស់សាលាឧទ្ធរណ៍ ។

១៨-ទណ្ឌិតឈ្មោះ **អាន ស្មៀង** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-៧-២០១០ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩១ "ឃ" ចុះថ្ងៃទី ២៣-៩-២០១០ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL

១៩-ទណ្ឌិតឈ្មោះ **អៀម រ៉េត** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៩-២០០៥ ពីបទ ធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ "ខ" ចុះថ្ងៃទី ០៦-៣-២០០៦ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

២០-ទណ្ឌិតឈ្មោះ **ផាន តិន** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-៤-២០១០ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ "ង" ចុះថ្ងៃទី ១៩-៩-២០១១ របស់សាលាដំបូងខេត្តបាត់ដំបង ។

**មាត្រា ៣ :** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ខែ ឱ្យទណ្ឌិតចំនួន ២៦នាក់ ក្នុងឱកាសបុណ្យពិសាខបូជា ឆ្នាំ២០១៦ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមៈ

១-ទណ្ឌិតឈ្មោះ **ឃី សុរិយា** ហៅ ជ្រូក ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៩-២០០៧ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤ "ខ" ចុះថ្ងៃទី ១៣-៣-២០០៨ របស់សាលាដំបូងខេត្តព្រះសីហនុ ។

២-ទណ្ឌិតឈ្មោះ **ធី ម៉ៅ** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-៨-២០០៦ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៩ "ក" ចុះថ្ងៃទី ១៣-៩-២០០៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

៣-ទណ្ឌិតឈ្មោះ **ចាន់ រដ្ឋា** ហៅ ផុង ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-៣-២០០៨ ពីបទ ធ្វើមនុស្សឃាតដោយចេតនា និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧០ "ឃ" ចុះថ្ងៃទី ២៨-៨-២០០៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

៤-ទណ្ឌិតឈ្មោះ **ទុយ ស្លា** ហៅ វុទ្ធី ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១០-០១-២០០៨ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩ "ឃ" ចុះថ្ងៃទី ២៩-៨-២០០៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

៥-ទណ្ឌិតឈ្មោះ **មឿន គីមឡុង** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី [illegible]-១១-២០១០ ពីបទ នាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦១ "ឃ" ចុះថ្ងៃទី ១១-៨-២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

៦-ទណ្ឌិតឈ្មោះ **ឃុន សត្យា** ហៅ មៅ ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣០-០១-២០០៧ ពីបទ ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ "ក" ចុះថ្ងៃទី ២៥-៧-២០០៦ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

៧-ទណ្ឌិតឈ្មោះ **ម្រេះ ញ៉ាយ** ភេទប្រុស អាយុ ៤៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-១២-២០០៨ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ១៨-៣-២០១០ របស់សាលាដំបូងខេត្តមណ្ឌលគិរី ។

៨-ទណ្ឌិតឈ្មោះ **មាស សំអាន** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣១-១០-២០០២ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៥០ ចុះថ្ងៃទី ០៤-៥-២០១៥ របស់តុលាការកំពូល ។

៩-ទណ្ឌិតឈ្មោះ **ណិម ប៉ាក់** ភេទប្រុស អាយុ ៥១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-១០-២០០៦ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ "គ" ចុះថ្ងៃទី ១៤-៣-២០០៧ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១០-ទណ្ឌិតឈ្មោះ **អ៊ឹង សុភាព** ភេទប្រុស អាយុ ៥១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៨-២០០៧ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៤ "ច" ចុះថ្ងៃទី ០១-៧-២០០៨ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១១-ទណ្ឌិតឈ្មោះ **ទៀម ហ៊ាន់** ភេទប្រុស អាយុ ៤៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៤-១២-២០០៤ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ "គ" ចុះថ្ងៃទី ០៦-៥-២០០៥ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១២-ទណ្ឌិតឈ្មោះ **ប៊ិន បត** ភេទប្រុស អាយុ ៥២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-៣-២០០៦ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៦ "ឃ" ចុះថ្ងៃទី ៣១-៧-២០០៦ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៣-ទណ្ឌិតឈ្មោះ **ទុំ ជួត** ភេទប្រុស អាយុ ៥០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-១២-២០០៥ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៤ "ឃ" ចុះថ្ងៃទី ០៩-៦-២០០៦ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៤-ទណ្ឌិតឈ្មោះ **មាស សេម** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១០-៨-២០០៦ ពីបទ ប៉ុនប៉ងធ្វើមនុស្សឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ "ខ" ចុះថ្ងៃទី ២៩-៤-២០០៧ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

១៥-ទណ្ឌិតឈ្មោះ **ហួរ សឿន** ភេទប្រុស អាយុ ៥៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៤-២០០៩ ពីបទ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៦ "ក" ចុះថ្ងៃទី ២៣-៦-២០១០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

១៦-ទណ្ឌិតឈ្មោះ **ម៉ុត ខន** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៣-៨-២០០៩ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៥ "ក" ចុះថ្ងៃទី ០១-៩-២០១០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

១៧-ទណ្ឌិតឈ្មោះ **ជោក ឡឿន** ភេទប្រុស អាយុ ៥៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-៤-២០០៩ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦២ "ក" ចុះថ្ងៃទី ២៦-៨-២០១០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

១៨-ទណ្ឌិតឈ្មោះ **មាស ឈឿង** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-៩-២០០៥ ពីបទ ធ្វើមនុស្សឃាតដោយគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩ "ខ" ចុះថ្ងៃទី ០៦-៣-២០០៦ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

១៩-ទណ្ឌិតឈ្មោះ **ហួន អឿន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-៦-២០០៩ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៥ "ង" ចុះថ្ងៃទី ២៩-៤-២០១០ របស់សាលាដំបូងខេត្តបាត់ដំបង ។

២០-ទណ្ឌិតឈ្មោះ **ងៀម ឡើន** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-១០-២០០៥ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩ "ខ" ចុះថ្ងៃទី ៣១-០១-២០០៦ របស់សាលាដំបូងខេត្តបាត់ដំបង ។

២១-ទណ្ឌិតឈ្មោះ **ថៅ ផល** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-១២-២០០៧ ពីបទ អំពើមនុស្សឃាតដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៩១ "ក្រ.vត" ចុះថ្ងៃទី ២១-១១-២០១២ របស់សាលាឧទ្ធរណ៍ ។

២២-ទណ្ឌិតឈ្មោះ **ចាន់ គា** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-១២-២០០៧ ពីបទ អំពើមនុស្សឃាតដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៩១ "ក្រ.vត" ចុះថ្ងៃទី ២១-១១-២០១២ របស់សាលាឧទ្ធរណ៍ ។

២៣-ទណ្ឌិតឈ្មោះ **ចាន់ ម៉ុនធឿន** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-១២-២០០៧ ពីបទ អំពើមនុស្សឃាតដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៩១ "ក្រ.vត" ចុះថ្ងៃទី ២១-១១-២០១២ របស់សាលាឧទ្ធរណ៍ ។

២៤-ទណ្ឌិតឈ្មោះ **ហៀ រ៉ា** ហៅ ចិន ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-១២-២០០៧ ពីបទ អំពើមនុស្សឃាតដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៩១ "ក្រ.vត" ចុះថ្ងៃទី ២១-១១-២០១២ របស់សាលាឧទ្ធរណ៍ ។

២៥-ទណ្ឌិតឈ្មោះ **ជុំ ញ៉េម** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-១១-២០០៥ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៦ "ក" ចុះថ្ងៃទី ២០-០២-២០០៩ របស់សាលាឧទ្ធរណ៍ ។

២៦-ទណ្ឌិតឈ្មោះ **អ៊ី លេខ** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-១២-២០០៥ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ "ច" ចុះថ្ងៃទី ២១-៤-២០០៦ របស់សាលាដំបូងខេត្តកំពង់ចាម ។

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

**មាត្រា ៤ :** ត្រូវលើកលែងទោសឱ្យទណ្ឌិតចំនួន ០៣នាក់ ក្នុងឱកាសបុណ្យពិសាខបូជា ឆ្នាំ២០១៦ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម៖

១-ទណ្ឌិតឈ្មោះ **ស៊ិន ស្រីឌី** ហៅ ឌៀន ភេទស្រី អាយុ ៣៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៧-៨-២០១៤ ពីបទ ឆបោក ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ "ឃ" ចុះថ្ងៃទី ០៥-០២-២០១៥ របស់សាលាដំបូងខេត្តកំពង់ចាម ។

២-ទណ្ឌិតឈ្មោះ **អេង នី** ភេទប្រុស អាយុ ៤៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣១-៧-២០១៤ ពីបទ ប្រទូស្តកេរខ្មាសមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ ដោយទោសនេះឱ្យអនុវត្តក្នុងពន្ធនាគាររយៈពេល ២ ឆ្នាំ ទោសនៅសល់ឱ្យព្យួរការអនុវត្តធម្មតា តាមអំណាចសាលក្រមលេខ ២៥ "ក" ចុះថ្ងៃទី ២៩-១២-២០១៤ របស់សាលាដំបូងខេត្តសៀមរាប ។

៣-ទណ្ឌិតឈ្មោះ **ឡៀង ធីហាយ** ភេទស្រី អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១១-៩-២០១១ ពីបទ សញ្ជារកម្មមានស្ថានទម្ងន់ទោស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣ "ច" ចុះថ្ងៃទី ២១-៦-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

**មាត្រា ៥ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.១៦០៥.៥៤៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦*

លេខៈ ៥៧៤ ស.ណ

**សំណៅចំលងចេញតាមច្បាប់ដើម**

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩៥ អនុក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១៦០ ០០០ ០០០ រៀល (មួយរយហុកសិបលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦៥ (ឧបត្ថម្ភធន) ជូនទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្តល់ជូនគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ សម្រាប់សាងសង់ទីស្នាក់ការសង្កេតការណ៍នៅកោះរ៉ុង។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៩៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៦ ស្តីពីការកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃការធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨
- បានឃើញអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

អនុក្រឹត្យនេះមានគោលបំណងធ្វើបច្ចុប្បន្នកម្មទិន្នន័យប្រជាជន ពង្រឹងនិងធ្វើឲ្យប្រសើរឡើងនូវការប្រមូល កែច្នៃ និងផ្សព្វផ្សាយទិន្នន័យប្រជាជន ក្នុងរយៈពេលកំណត់មួយនៅក្នុងប្រទេស សម្រាប់អ្នកប្រើប្រាស់ និងអ្នករៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោងនានាក្នុងផែនការអភិវឌ្ឍ។

**មាត្រា២ ..**

អនុក្រឹត្យនេះមានគោលដៅកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨។

**មាត្រា៣ ..**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើប្រជាជនទាំងប្រុស ទាំងស្រី ទាំងក្មេង ទាំងចាស់ ដើម្បីទទួលបាននូវព័ត៌មាន ប្រជាសាស្ត្រដូចជា អាយុ ភេទ ស្ថានភាពអាពាហ៍ពិពាហ៍ និងព័ត៌មានគន្លឹះពីសេដ្ឋកិច្ចគ្រួសារ ការងារ ការអប់រំ និងសុខភាពរបស់ប្រជាជននៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ ..**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ជំរឿនប្រជាជន** សំដៅដល់ការរាប់ចំនួនប្រជាជនទាំងប្រុស ទាំងស្រី ទាំងក្មេង ទាំងចាស់ និងទាំងជនជាតិខ្មែរ ទាំងជនបរទេស លើកលែងតែមន្ត្រីអង្គទូតនិងក្រុមជនដូចគ្នានឹងអង្គទូត ដែលកំពុងរស់នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។
- **ប្រជាជន** សំដៅដល់មនុស្សដែលរស់នៅក្នុងប្រទេសណាមួយឬលក្ខណៈសម្គាល់ ប្រជាសាស្ត្រ សង្គម ឬសេដ្ឋកិច្ច ( ភេទ អាយុ ប្រភេទកន្លែងរស់នៅ។ល។)
- **ប្រជាសាស្ត្រ** សំដៅដល់ការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រអំពីប្រជាជន រួមមានទំហំ សមាសភាព របាយដង់ស៊ីតេ កំណើន និងលក្ខណៈសម្គាល់ផ្សេងៗទៀតរបស់ប្រជាជន ព្រមទាំងហេតុនិងផលវិបាកនៃការប្រែប្រួលកត្តាទាំងនេះ។

## ជំពូកទី២

## កាលបរិច្ឆេទ

**មាត្រា៥ ..**

កំណត់កាលបរិច្ឆេទសម្រាប់ដំណើរការជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា នៅម៉ោងសូន្យ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៨។

## ជំពូកទី៣

## យន្តការនិងនីតិវិធី

**មាត្រា៦ ..**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨ ដែលមានសមាសភាពដូចខាងក្រោម៖

១- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន

២- រដ្ឋមន្ត្រីក្រសួងផែនការ អនុប្រធាន

៣- រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក



| | |
|---|---|
| ៤- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| ៥- រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប | សមាជិក |
| ៦- រដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម ១រូប | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប | សមាជិក |
| ១៧- រដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប | សមាជិក |
| ១៨- អនុរដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| ១៩- អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជនត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៧ ..**

គណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨ មានភារកិច្ចៈ

- ណែនាំនិងអនុម័តរាល់កិច្ចការទូទៅដែលពាក់ព័ន្ធនឹងជំរឿនទូទៅប្រជាជន
- រៀបចំនិងបង្កើតគណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននិងគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជន មានទីស្នាក់ការនៅក្រសួងផែនការនិងស្ថិតក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងផែនការ សម្រាប់អនុវត្តផ្ទាល់រាល់ការងារបច្ចេកទេសជំរឿនទូទៅប្រជាជន
- រៀបចំនិងបង្កើតគណៈកម្មាធិការជំរឿនទូទៅប្រជាជនគ្រប់រាជធានីខេត្ត
- តែងតាំងមន្ត្រីឲ្យចូលរួមជំរឿនទូទៅប្រជាជន តាមការស្នើសុំពីគណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជន
- ប្រជុំការងារតាមរបបប្រជុំត្រីមាស តាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការឬអនុប្រធានគណៈកម្មាធិការ នៅពេលដែលប្រធានគណៈកម្មាធិការអវត្តមាន
- ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពីការប្រព្រឹត្តទៅនិងលទ្ធផលនៃជំរឿនទូទៅប្រជាជន។

**មាត្រា៨ ..**

